វិទ្យាស្ថានបើកទូលាយ
Open Institute

# របាយការណ៍វេទិកាពិភាក្សា

# ស្តីពី

# "តួនាទីយុវជនក្នុងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន"



ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៣

**ឧបត្ថម្ភថវិកាដោយៈ**

SPIDER

# មាតិកា

១. ព័ត៌មានទូទៅ.....១
២. សេចក្តីផ្តើម.....១
៣. គោលបំណងនៃវេទិកាពិភាក្សា.....២
៤. ការរំពឹងទុកនៃវេទិកាពិភាក្សា.....២
៥. របៀបវារៈនៃវេទិកាពិភាក្សា.....២
៦. ខ្លឹមសារលំអិតនៃវេទិកាពិភាក្សា.....៣
៧. លទ្ធផលនៃវេទិកាពិភាក្សា.....១៨
៨. ការវាយតម្លៃនៃវេទិកាពិភាក្សា.....២០
ឧបសម្ពន្ធ១៖.....២២

# របាយការណ៍វេទិកាពិភាក្សា
# ស្តីពី
# "តួនាទីយុវជនក្នុងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន"

## ១. ព័ត៌មានទូទៅ-

- រៀបចំដោយ ៖ សម្ពន្ធភាពជាតិ ឃុំ សង្កាត់ និង អង្គការវិទ្យាស្ថានបើកទូលាយ
- កាលបរិច្ឆេទ ៖ ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៣
- ពេលវេលា ៖ ម៉ោង ៨:០០-១២:០០
- រយៈពេល ៖ ៤ម៉ោង
- ទីកន្លែង ៖ អង្គការវិទ្យាស្ថានបើកទូលាយ
- សម្របសម្រួលដោយ ៖ អង្គការវិទ្យាស្ថានបើកទូលាយ
- សមាជិកចូលរួមក្នុងវេទិកា ៖ ៤០នាក់(ស្ត្រី២០នាក់ បុរស២០នាក់)
  - តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ (៨រូប)
  - តំណាងស្ថាប័នរាជរដ្ឋាភិបាល (២រូប)
  - តំណាងម្ចាស់ជំនួយ (១រូប)
  - តំណាងអង្គការមិនមែនរដ្ឋាភិបាល (២៥រូប)
  - តំណាងអ្នកសារព័ត៌មាន (៣រូប)
  - តំណាងក្រុមហ៊ុនឯកជន (១រូប)

## ២. សេចក្តីផ្តើម

វិទ្យាស្ថានបើកទូលាយ សហការជាមួយសម្ព័ន្ធភាពជាតិ ឃុំ សង្កាត់បានរៀបចំវេទិកាពិភាក្សាមួយស្តីពី"តួនាទីយុវជនក្នុងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន" នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០១៣។ ចូលរួមនៅក្នុងឱកាសនោះមានតំណាងមកពី ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សមាគមឃុំសង្កាត់ខេត្តបាត់ដំបង សៀមរាប កណ្តាល និង ភ្នំពេញ The Swedish Program for ICT in Developing Regions(Spider) មជ្ឈមណ្ឌលកម្ពុជា

ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ អង្គការយុវជនខ្មែរនិងការអភិវឌ្ឍសង្គម សមាគមអភិវឌ្ឍសុខភាពប្រជាជន អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន សមាគមយុវជនខ្មែរ អង្គការស្ពានកម្ពុជា អង្គការយុវតារា វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ក្រុមអ្នកស្រាវជ្រាវ និងអង្គការវិទ្យាស្ថានបើកទូលាយ។

## ៣. គោលបំណងនៃវេទិកាពិភាក្សា

វេទិកាពិភាក្សាធ្វើឡើងក្នុងគោលបំណង៖

- ផ្តល់ចំណេះដឹងដល់យុវជនស្តីពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ឃុំ សង្កាត់ យោងតាមច្បាប់ស្តីពី "ការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់" សម្រាប់ការចូលរួមដ៏មានប្រសិទ្ធភាពជាមួយក្រុមប្រឹក្សាឃុំ សង្កាត់។
- កំណត់យុទ្ធសាស្ត្រនៃការចូលរួមដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរនៃការធ្វើសេចក្តីសម្រេចចិត្តចាប់តាំងពីការកសាងផែនការ ការអនុវត្តន៍ផែនការ គោលនយោបាយ កម្មវិធី និងសេវាកម្មដែលផ្តល់ជូនជាមួយនឹងគុណភាព ប្រសិទ្ធភាពនៅថ្នាក់ក្រោមជាតិជាពិសេសគឺថ្នាក់ឃុំសង្កាត់។

## ៤. ការរំពឹងទុកនៃវេទិកាពិភាក្សា

នៅចុងបញ្ចប់វេទិកាពិភាក្សានេះ អ្នកចូលរួមដែលជាក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីក្រសួង បុគ្គលិកនិងយុវជនតំណាងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មាននឹងទទួលបានចំណេះដឹង និងព័ត៌មានថ្មីទាក់ទងនឹង៖

- ស្ថានភាព និងតួនាទីការចូលរួមរបស់យុវជនក្នុងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន
- ការបារម្ភ ឧបសគ្គ និងដំណោះស្រាយជាយុទ្ធសាស្ត្រដែលអាចលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន
- យុវជន និងក្រុមប្រឹក្សាអាចធ្វើការចែករំលែកលើបញ្ហានានាទាក់ទង និងការងារការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន

## ៥. របៀបវារៈនៃវេទិកាពិភាក្សា

ម៉ោង ៧:៤៥-ម៉ោង ៨:០០ ការចុះឈ្មោះ

| | |
|---|---|
| ម៉ោង ៨:០០-ម៉ោង ៨:១០ | មតិស្វាគមន៍របស់លោកស្រីនាយិកាអង្គការវិទ្យាស្ថានបើកទូលាយ |
| ម៉ោង ៨:១០-ម៉ោង ៨:២០ | ចំណាប់អារម្មណ៍ស្វាគមន៍របស់តំណាងសម្ព័ន្ធភាពជាតិឃុំ/សង្កាត់ |
| ម៉ោង ៨:២០-ម៉ោង ៨:៣៥ | បទបង្ហាញអំពីគម្រោង"កិច្ចពិភាក្សាអំពីការអភិវឌ្ឍន៍" |
| ម៉ោង ៨:៣៥-ម៉ោង ៨:៥៥ | បទបង្ហាញស្តីពី"កម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) និងផែនការអនុវត្ត ៣ឆ្នាំរំកិល(ផ.អ.៣)" |
| ម៉ោង ៨:៥៥-ម៉ោង ៩:២០ | បទបង្ហាញស្តីពី"ការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ដំណើរការនៃកម្មវិធីវិនិយោគ(CIP), ផែនការអភិវឌ្ឍ(CDP) លទ្ធកម្មឃុំ/សង្កាត់ និងរបៀបដែលយុវជនអាចចូលរួមក្នុងដំណើរការទាំងនោះបាន" |
| ម៉ោង ៩:២០-ម៉ោង ៩:៤០ | បទបង្ហាញស្តីពី"បទពិសោធន៍នៃការធ្វើសមាហរណកម្មយុវជនក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន" |
| ម៉ោង ៩:៤០-ម៉ោង ១០:០០ | សម្រាកពិសាអាហារសម្រន់ |
| ម៉ោង ១០:០០-ម៉ោង ១១:៣០ | ពិភាក្សាពេញអង្គលើប្រធានបទរបស់វេទិកាពិភាក្សា<br>១. ហេតុអ្វីប្រជាពលរដ្ឋដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនៃអភិបាលកិច្ចល្អ?<br>២. តើយុវជនមានតួនាទីយ៉ាងដូចម្តេចខ្លះដើម្បីរួមចំណែកលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងសហគមន៍របស់ពួកគេ?<br>៣. តើយុវជនអាចចូលរួមក្នុងសកម្មភាពនានារបស់ឃុំ/សង្កាត់បានយ៉ាងដូចម្តេច?<br>៤. តើយុវជនទទួលបានប្រយោជន៍អ្វីខ្លះពីការចូលរួមក្នុងការងារមូលដ្ឋានជាពិសេសនៅក្នុងអភិបាលកិច្ចឃុំសង្កាត់?<br>៥. តើមានយុទ្ធសាស្រ្តអ្វីខ្លះដែលអាចលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការពង្រឹងការអភិវឌ្ឍន៍មូលដ្ឋាននិងអភិបាលកិច្ចមូលដ្ឋាន? |
| ម៉ោង ១១:៣០-ម៉ោង ១១:៤៥ | វាយតម្លៃពាក់កណ្តាលគម្រោងនៃគម្រោង"កិច្ចពិភាក្សាអំពីការអភិវឌ្ឍ" |
| ម៉ោង ១១:៤៥-ម៉ោង ១២:០០ | សរុបលទ្ធផលវាយតម្លៃ និងបិទកម្មវិធី |

## ៦. ខ្លឹមសារលំអិតនៃវេទិកាពិភាក្សា

### មតិស្វាគមន៍របស់លោកស្រី ជឹម ម៉ាណាវី នាយិកាអង្គការវិទ្យាស្ថានបើកទូលាយ

លោកស្រី ជឹម ម៉ាណាវី នាយិកា ប្រតិបត្តិនៃអង្គការវិទ្យាស្ថានបើកទូលាយ បានមានប្រសាសន៍ស្វាគមន៍ក្នុងឱកាសបើកវេទិកាពិភាក្សាដោយបានលើកបង្ហាញអំពីវគ្គសិក្សាពីមុនៗដែលអង្គការវិទ្យាស្ថានបើកទូលាយបានរៀបចំពេលកន្លងទៅ.ៗវគ្គបណ្តុះបណ្តាលទាំងនោះរួមមាន អំពី "សិទ្ធចូលទៅកាន់ព័ត៌មាន" "របៀបសរសេរព័ត៌មាន" និងកិច្ចពិភាក្សាស្តីពី "យុវជនក្នុងការបោះឆ្នោតថ្នាក់ជាតិ"។ លោកស្រីមានប្រសាសន៍ថា ឱកាសនេះគឺជាការជួបគ្នាម្តងទៀត រវាងក្រុមប្រឹក្សាឃុំសង្កាត់ និងយុវជនពីតំណាងអង្គការដៃគូនិងអង្គការពាក់ព័ន្ធនានា ក្នុងវេទិកាពិភាក្សា ស្តីអំពី "យុវជនក្នុងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន" សហការរៀបចំដោយសម្ព័ន្ធភាពជាតិ ឃុំ សង្កាត់ និងអង្គការវិទ្យាស្ថានបើកទូលាយ។ លោកស្រីបន្តថា គោលបំណងទូទៅនៃវេទិកានេះគឺបង្កើនឱកាសសម្រាប់ការស្វែងយល់គ្នាទៅវិញទៅមករវាងយុវជន និងក្រុមប្រឹក្សាឃុំសង្កាត់ ស្តីពីការចូលរួមរបស់យុវជន និងដំណើរការក្នុងការធ្វើសេចក្តីសម្រេចចិត្ត ចាប់តាំងពីការកសាងផែនការ ការអភិវឌ្ឍ ការអនុវត្តន៍ផែនការ គោលនយោបាយកម្មវិធីនិងសេវាកម្មទៅដល់ថ្នាក់ក្រោមជាតិ ជាពិសេសទៅដល់ថ្នាក់ឃុំ សង្កាត់។ គោលបំណងជាក់លាក់ គឺដើម្បីផ្តល់ចំណេះដឹងដល់យុវជនស្តីពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ឃុំ សង្កាត់ យោងតាមច្បាប់ស្តីពី"ការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់" សម្រាប់ការចូលរួមដ៏មានប្រសិទ្ធភាពជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងកំណត់យុទ្ធសាស្រ្តនៃការចូលរួមដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរនៃការធ្វើសេចក្តីសម្រេចចិត្ត ចាប់តាំងពីការកសាងផែនការ ការអនុវត្តន៍ផែនការ គោលនយោបាយ កម្មវិធី និងសេវាកម្មដែលផ្តល់ជូនជាមួយនិងគុណភាព ប្រសិទ្ធភាពនៅថ្នាក់ក្រោមជាតិជាពិសេសគឺថ្នាក់ឃុំ សង្កាត់។



*លោកស្រីជឹម ម៉ាណាវី នាយិកាប្រតិបត្តិអង្គការវិទ្យាស្ថានបើកទូលាយមានមតិស្វាគមន៍ក្នុងវេទិកាពិភាក្សាស្តីពី"យុវជនក្នុងការអភិវឌ្ឍមូលដ្ឋាននិងអភិបាលកិច្ចមូលដ្ឋាន"*

*រូបភាព៖ អង្គការវិទ្យាស្ថានបើកទូលាយ*

លោកស្រីនាយិកាបានថ្លែងបន្តថា ការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍ និងអភិបាលកិច្ចមូលដ្ឋានគឺមានសារសំខាន់ណាស់ យុវជនត្រូវបានលើកទឹកចិត្តអោយចូលរួមធ្វើផែនការ សម្រាប់ធ្វើសេចក្តីសម្រេចចិត្តក្នុងការអភិវឌ្ឍ និងដើម្បីលិទ្ធប្រជាធិបតេយ្យដ៏រឹងមាំមួយដែលមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ។ លោកស្រីបានបញ្ជាក់ថា គ្មានលទ្ធិប្រជាធិបតេយ្យដ៏រឹងមាំណាមួយគ្មានការចូលរួមរបស់យុវជននោះទេ ពីព្រោះ៣០%នៃប្រជាពលរដ្ឋកម្ពុជាគឺជាយុវជនដែលមានអាយុចន្លោះពី១៥ឆ្នាំដល់៣០ឆ្នាំ។ ដូច្នេះការចូលរួមរបស់យុវជនគឺមានសារសំខាន់បំផុតក្នុងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន។ ក៏ប៉ុន្តែគួរអោយស្តាយដោយយើងសង្កេតឃើញថាយុវជនត្រូវបានគេចាត់ទុកជាក្រុមងាយរងគ្រោះ ហើយមិនសូវមានការចូលរួមក្នុងការងារនយោបាយ និងការអភិវឌ្ឍនោះឡើយ។ បើ


ប្រអប់សំបុត្រលេខ ១៥៥២ ទូរស័ព្ទ(៨៥៥-២៣) ២២៤ ៨២១ អ៊ីមែល៖ openinstitute@open.org.kh វិប សាយ៖ http://open.org.kh

ទោះបីជា រាជរដ្ឋាភិបាលមានគោលនយោបាយលើកទឹកចិត្តដល់យុវជននោះក្តី តែយុវជននៅតែយល់ឃើញខ្លួនឯងថា ការងារអភិបាលកិច្ចមូលដ្ឋានគឺជាការងាររបស់មនុស្សវ័យចំណាស់ ឬមន្ត្រីសាធារណៈ ហើយការងារទាំងនោះមិនមានការពាក់ព័ន្ធនិងមានសារសំខាន់ចំពោះខ្លួនទេ។ ដោយសារការមិនស្គាល់ពីតួនាទីរបស់ខ្លួនឯង ដោយខ្វះការគាំទ្រសំឡេងយុវជន ព្រមទាំងកង្វះខាតនៃការបង្កភាពងាយស្រួលក្នុងការចូលរួមរបស់យុវជន និងដោយយុវជនមួយចំនួនខ្វះការយល់ដឹងពីរបៀបចូលរួមក្នុងការងាររបស់ឃុំ សង្កាត់ នោះ នាពេលបច្ចុប្បន្នយុវជនពេលខ្លះត្រូវបានគេចាត់ទុកជាបញ្ហា ពីសំណាក់សង្គមនិងមនុស្សវ័យចំណាស់។ ក៏ប៉ុន្តែប្រសិនបើយើងផ្តល់ឱកាសអោយយុវជនចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត នោះយុវជននឹងក្លាយជាសម្បត្តិធនធានសម្រាប់ឃុំ សង្កាត់ក្នុងការស្វែងរកដំណោះស្រាយអភិវឌ្ឍសម្រាប់ឃុំ សង្កាត់របស់ខ្លួន។ យ៉ាងណាមិញយើងគួរលើកទឹកចិត្ត និងធ្វើការជំរុញអោយយុវជនយល់ដឹងពីការទទួលខុសត្រូវរបស់ខ្លួននៅក្នុងសង្គម ដើម្បីប្រព្រឹត្តខ្លួនជាពលរដ្ឋសកម្មនៅក្នុងភូមិ ឃុំរបស់ពួកគេតាមរយៈការជំរុញសំឡេងយុវជនអោយមានឥទ្ធិពលក្នុងដំណើរការនិងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងដំណើរការអភិបាលកិច្ចមូលដ្ឋាន។

នៅក្នុងវេទិកានោះផងដែរ លោកស្រីនាយិកាបានចែករំលែកវិធីសាស្ត្រ ដើម្បីជំរុញការចូលរួមរបស់យុវជន តាមរយៈការបង្កើតឱកាសអោយយុវជនបានចូលរួមក្នុងកិច្ចពិភាក្សាអំពីអភិបាលកិច្ច និងតួនាទីយុវជនអោយកាន់តែច្រើន ដើម្បីអោយយុវជនទទួលបានព័ត៌មាន ធ្វើការវិភាគ និងធ្វើការបង្ហាញពីកង្វល់របស់យុវជនជូនទៅរាជរដ្ឋាភិបាល និងលើកកម្ពស់ការចូលរួមពេញលេញរបស់យុវជនក្នុងការអភិវឌ្ឍអោយកាន់តែច្រើនក្នុងសហគមន៍និងមូលដ្ឋាន សម្រាប់កាត់បន្ថយភាពក្រីក្រ និងអោយមានការផ្លាស់ប្តូរជាវិជ្ជមាន បង្កលក្ខណៈងាយស្រួលសមស្របសម្រាប់យុវជនមានបណ្តាញ ធ្វើការចែករំលែកចំណេះដឹងបានមកពីការរៀនសូត្រអំពីអភិបាលកិច្ចល្អ ជំរុញទាក់ទាញទឹកចិត្តយុវជនអោយស្វែងយល់ពីផលប៉ះពាល់ពីការសម្រេចចិត្តរបស់ឃុំសង្កាត់ទៅលើជីវិតរបស់ពួកគេ ព្រមទាំងទៅលើសារសំខាន់នៃការចូលរួមរបស់ពួកគេដើម្បីឲ្យមានបំឡាស់ប្តូរជាវិជ្ជមាន បង្កើនការយល់ដឹងពីតម្លៃពីការធ្វើការរួមគ្នារវាងក្រុមប្រឹក្សាឃុំ សង្កាត់និងយុវជន។

លោកស្រីបានសង្ឃឹមទុកជាមុនថា វេទិកាពិភាក្សានេះនឹងជួយជំរុញ សិក្ខាកាមជាយុវជននឹងបានយល់ដឹងបន្ថែមលើចំណុចសំខាន់ៗនៃតួនាទីរបស់ខ្លួន ក្រោយពីបានស្តាប់និងទទួល ពីការពិភាក្សារបស់អ្នកចូលរួមទាំងអស់គ្នាយ៉ាងស៊ីជម្រៅនិងផុសផុលទៅលើប្រធានបទនីមួយៗ។ ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នឹងបានស្វែងយល់ការលំបាកផ្សេងៗរបស់យុវជនក្នុងការចូលរួមក្នុងអភិបាលកិច្ចល្អ។

លោកស្រីក៏បានបញ្ជាក់ថានេះជាវេទិកាលើកទី២ បន្ទាប់វេទិកាលើកទី១ស្តីអំពី"យុវជនក្នុងការបោះឆ្នោតថ្នាក់ជាតិ ២០១៣ " ដែលត្រូវបានរៀបចំឡើងនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២កន្លងមក។

## បទបង្ហាញអំពីគម្រោង " កិច្ចពិភាក្សាអំពីការអភិវឌ្ឍ "

កញ្ញា កាំង សាណារី ប្រធានគម្រោងនៃអង្គការវិទ្យាស្ថានបើកទូលាយបានបង្ហាញអំពី″គម្រោងកិច្ចពិភាក្សាអំពីការអភិវឌ្ឍ″ ដែលជាឈ្មោះគម្រោងថ្មីរបស់គម្រោង " កិច្ចពិភាក្សាលើលិទ្ធប្រជាធិបតេយ្យ " ដែលទទួលបានជំនួយឧបត្ថម្ភថវិកាពី The Swedish Program for ICT in Developing Regions (Spider) ប្រទេសស៊ុយអែត ។ នៅក្នុងប្រទេសកម្ពុជាគម្រោងនេះកំពុងធ្វើការទៅលើយុវជន និងជាមួយក្រុមប្រឹក្សាឃុំសង្កាត់។ កញ្ញាបានឲ្យដឹងថា ដោយសារមើលឃើញសកម្មភាពចូលរួមរបស់យុវជន ទៅលើសិទ្ធិឬលទ្ធិប្រជាធិបតេយ្យរបស់ពួកគាត់មានភាពអសកម្ម និងមានកំណត់ ក្នុងការចែករំលែកនូវបទពិសោធន៍ និងការចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្តក្នុងការងារអភិវឌ្ឍ និងដោយយល់ឃើញថា ពួកគាត់មិនសូវមានសកម្មភាពក្នុងការទ្រទ្រង់ ក្នុងលទ្ធិប្រជាធិបតេយ្យឬការបោះឆ្នោត ម្យ៉ាងទៀតយុវជនគិតថាចំណេះដឹងរបស់គាត់នៅមានកម្រិត នោះទើបគម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់ជួយអោយយុវជននិងក្រុមប្រឹក្សាឃុំធ្វើការស្វែងយល់ពីគ្នាទៅវិញទៅមក។

កញ្ញាណារីក៏បានឲ្យដឹងទៀតថាគម្រោងនេះមានគោលបំណង ចង់បង្កើតបរិស្ថានមួយដែលមានការពិភាក្សាជាប្រព័ន្ធលើការអភិវឌ្ឍ រវាងយុវជននិងក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងរាជធានីភ្នំពេញ បាត់ដំបង សៀមរាប កណ្ដាល កំពង់ឆ្នាំង និង ក្រចេះ តាមរយៈការប្រើប្រាស់ICTសម្រាប់ការចូលរួមដ៏ប្រសើរក្នុងដំណើរការនៃលិទ្ធប្រជាធិបតេយ្យ។ គម្រោងនេះបាននិងកំពុងធ្វើការរួមជាមួយដៃគូគម្រោងចំនួនបួនសំខាន់ៗគឺ សម្ពន្ធភាពឃុំ សង្កាត់ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ អង្គការយុវជនខ្មែរនិងការអភិវឌ្ឍសង្គម សមាគមអភិវឌ្ឍសុខភាពប្រជាជន។

កញ្ញាណារីក៏បានបន្តទៀតថាគម្រោងនេះមានគោលបំណងជាក់លាក់បី៖ ទី១ចង់ឃើញយុវជននិងក្រុមប្រឹក្សាឃុំសង្កាត់ មានចំណេះដឹងទាក់ទងទៅនឹងសិទ្ធទទួលព័ត៌មាន និងប្រើប្រាស់ICT សម្រាប់ធ្វើការចែករំលែកព័ត៌មានរបស់គាត់ហើយនឹងដើម្បីចូលរួមក្នុងការអភិវឌ្ឍនៅក្នុងសង្គមជាមួយការតស៊ូមតិផ្សេងៗ ។ គោលបំណងទី២គឺចង់អោយមានកន្លែងបើកចំហមួយដោយសេរីពិភាក្សាជាមួយនឹងការជជែកដេញដោលលើលិទ្ធប្រជាធិបតេយ្យ និងការពិភាក្សាអំពីការបោះឆ្នោតសម្រាប់យុវជនជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកធ្វើការពាក់ព័ន្ធផ្សេងៗទៀត។ គោលបំណងទី៣គឺយើងចង់បង្កើតជាយុទ្ធនាដើម្បីចែករំលែកព័ត៌មានតាមរយៈការប្រើប្រាស់ICT ពិភាក្សាទៅលើការបោះឆ្នោត សិទ្ធិមនុស្ស អភិបាលកិច្ចល្អ និងដំណើរការល្អលើលទ្ធិប្រជាធិបតេយ្យ។

សកម្មភាពរបស់គម្រោងមាន៣សំខាន់ៗដូចជា វគ្គបណ្ដុះបណ្ដាល ការពិភាក្សាទៅលើលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍ និងយុទ្ធនាការព័ត៌មានទាក់ទងនឹងលទ្ធិប្រជាធិបតេយ្យ ទាក់ទងនឹងវគ្គបណ្ដុះបណ្ដាល សម្រាប់យុវជននិងក្រុមប្រឹក្សាឃុំ សង្កាត់។

កញ្ញាបានថ្លែងប្រាប់ក្រុមសិក្ខាកាមថាសកម្មភាពនានាដែលធ្វើបានកន្លងមករបស់អង្គការវិទ្យាស្ថានបើកទូលាយ និងអង្គការដៃគូមានដូចជា៖ ការបណ្តុះបណ្តាលចំនួនពីរវគ្គ ស្តីអំពី"ICT និងសារព័ត៌មានប្រជាពលរដ្ឋ" និងបានរៀបចំវេទិកាពិភាក្សាចំនួនមួយ។ ចំពោះដៃគូគម្រោងដូចជា សមាគមអភិវឌ្ឍសុខភាពប្រជាជនបានរៀបចំនិងដំណើរការធ្វើការជជែកដេញដោលរវាងនិស្សិតនិងនិស្សិត ដែលចាក់ផ្សាយតាមរយៈទូរទស្សន៍ជាតិនិងវិទ្យុចំនួនពីរដង។ អង្គការយុវជនខ្មែរនិងការអភិវឌ្ឍសង្គម បានរៀបចំយុទ្ធនាការសម្រាប់ធ្វើការអប់រំផ្សព្វផ្សាយចំនួនពីរដង។ សម្រាប់វិទ្យាស្ថានបើកទូលាយផ្ទាល់ជាអ្នករៀបចំវេទិកាពិភាក្សាទៅលើលទ្ធិប្រជាធិបតេយ្យ ចំនួនពីរដងរួមជាមួយនឹងវេទិកានេះ។ វិទ្យាស្ថានក៏បានរៀបចំសិក្ខាសាលាស្តីអំពីការប្រើប្រាស់ICT ដល់យុវជន ដើម្បីអោយមានការចូលរួមកាន់តែផុសផុលលើដំណើរការលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។ ក៏មានការចែករំលែក និងកិច្ចពិភាក្សាតាមវិទ្យុ ហៅថា"Radio Talk Show" បានរៀបចំឡើងដោយ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដែល ជាដៃគូរបស់គម្រោងD&Dផងដែរ ។ ហើយគម្រោងក៏មានយុទ្ធនាការព័ត៌មានលទ្ធិប្រជាធិបតេយ្យ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា Facebook និងTwitter ដែលគ្រប់ដៃគូទាំងអស់មាន Page រៀងៗខ្លួន។ គម្រោងបានចែកបណ្ណ័ប្រកាសចំនួន៣០០០០ និង៦០០០០ស្ទីកគ័រទៅដល់ក្រុមគោលដៅ។ សកម្មភាពទាំងអស់ត្រូវបានផ្សព្វផ្សាយតាមផតថលរបស់ស្ត្រីនិងតាមរយៈប្រព័ន្ធផ្សព្វផ្សាយដទៃៗទៀត។ ហើយនៅចុងបញ្ចប់នៃគម្រោងនឹងមានការវាយតម្លៃគម្រោង។

## បទបង្ហាញពី"កម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងផែនការអនុវត្ត ៣ឆ្នាំរំកិល(ផ.អ.៣)" ដោយលោក សុខ សុធី អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍគោលនយោបាយរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ

លោកសុខ សុធីតំណាងក្រសួងមហាផ្ទៃ និងជាអនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍគោលនយោបាយនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិNCDD បានធ្វើបទបង្ហាញ ស្តីពី "កម្មវិធីវិនិយោគ៣ឆ្នាំរំកិល" ដែលពេលបច្ចុប្បន្នបានប្តូរឈ្មោះជា"ផែនការអភិវឌ្ឍរយៈពេល៣ឆ្នាំ"។ លោកមានប្រសាសន៍ថាជាទូទៅអង្គភាពវិភាគនិងអភិវឌ្ឍគោលនយោបាយគឺជាអ្នករៀបចំគោលនយោបាយទាំងអស់ ចេញទៅរដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកអនុវត្តន៍។ លោកបានជម្រាបជូនដល់អ្នកចូលរួមអំពីប្រវត្តិសង្ខេបអំពីការចាប់ផ្តើមធ្វើកំណែទម្រង់ចាប់តាំងពីឆ្នាំ២០០១ក្រោយពីយើងបោះឆ្នោតជ្រើសតាំងរដ្ឋសភាឆ្នាំ១៩៩៨។ រដ្ឋាភិបាលក៏បានផ្តួចផ្តើមគំនិតក្នុងការធ្វើការកំណែទម្រង់មួយហៅថាវិមជ្ឈការ និងវិសហមជ្ឈការ។ ច្បាប់ក្នុងការគ្រប់គ្រងរដ្ឋបាលស្រុក ខណ្ឌត្រូវបានបង្កើតនៅក្នុងឆ្នាំ២០០១

ដែលបានតម្រូវអោយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានស្វ័យភាពខ្លួនឯងនៅក្នុងការអភិវឌ្ឍចាប់ពីឆ្នាំ២០០២។ ក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធសម្រេចលើការអភិវឌ្ឍផ្ទាល់ ដោយរដ្ឋាភិបាលបានយល់ឃើញថា ការធ្វើការរបស់ឃុំ សង្កាត់បានយល់ដឹងច្បាស់នូវតម្រូវការប្រជាពលរដ្ឋនៅក្នុងឃុំរបស់ខ្លួន ហើយរដ្ឋាភិបាលចង់កាត់បន្ថយភាពក្រីក្រ ដូច្នេះការមានក្រុមប្រឹក្សាឃុំ សង្កាត់នឹងបម្រើដល់ផលប្រយោជន៍យ៉ាងច្រើន។

ក្នុងរយៈពេលតែ៣ឆ្នាំចាប់ពីឆ្នាំ២០០២ នៃការធ្វើការរបស់ឃុំ សង្កាត់ យើងសង្កេតឃើញថាការលូតលាស់របស់ភូមិសង្កាត់មានលក្ខណៈប្លែកគួរអោយកត់សម្គាល់។ រដ្ឋាភិបាលបានរៀនសូត្របណ្តើរនឹងធ្វើការអនុវត្តន៍បណ្តើរ ដើម្បីឈានដល់ការធ្វើកំណែទម្រង់ស៊ីជម្រៅមួយហៅថា វិមជ្ឈការ និងវិសហមជ្ឈការ ដែលកំណត់ដោយគណៈរដ្ឋមន្ត្រី នៅ ក្នុងឆ្នាំ២០០៥។ ហើយនៅក្នុងឆ្នាំ២០០៨ មានច្បាប់មួយចេញបន្ថែមទៀតស្តីពី"ការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុក ខណ្ឌ" និងច្បាប់ស្តីពី "ច្បាប់រដ្ឋបាលឃុំ សង្កាត់" ។

លោកសុខ សុធីក៏បានបញ្ជាក់ថាច្បាប់ស្តីពី"ការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ" និងច្បាប់ស្តីពី"ច្បាប់រដ្ឋបាលឃុំសង្កាត់"ទាំងពីរនេះហើយដែលជនបរទេសភាគច្រើនហៅថាច្បាប់រៀបចំអង្គការឬច្បាប់គ្រប់គ្រងអង្គការឬសមាគម។ ទាក់ទងនឹងច្បាប់ទាំងពីរនោះដែរ លោកបានបញ្ជាក់ថាច្បាប់នេះគឺស្ថិតនៅក្រោមតែរដ្ឋធម្មនុញ្ញតែមួយប៉ុណ្ណោះ ពីព្រោះនៅក្នុងរដ្ឋធម្មនុញ្ញបានចែងថាច្បាប់រៀបចំអង្គការនេះគឺតម្រូវអោយរៀបចំនូវស្ថាប័នអនុវត្តន៍របស់ជាតិទាំងមូល។

លោកបានមានប្រសាសន៍បន្តថា អង្គភាពវិភាគនិងអភិវឌ្ឍគោលនយោបាយរបស់លោក គឺជាអ្នករៀបចំសរសេរច្បាប់ស្តីពីការបោះឆ្នោត រហូតដល់ការចេញច្បាប់ស្តីពី"ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ" ។ ការសរសេរច្បាប់នេះគឺយកលំនាំខ្មែរ និងការយកលំនាំមកកែសម្រួលផ្សេងៗ។ ចាប់តាំងពីឆ្នាំ២០១១ការធ្វើកំណែទម្រង់មានទស្សនវិស័យវែង ដែលត្រូវការរយៈពេល៤០ឆ្នាំក្នុងការធ្វើកំណែទម្រង់ ហើយត្រូវការចំណាយថវិកាប្រហែលប្រាំបីពាន់លានដុល្លារ ដែលបានគ្រោងទុករួចជាស្រេច។ ដូចនេះអង្គភាពវិភាគនិងអភិវឌ្ឍគោលនយោបាយ លេខាធិការដ្ឋាន គ .ជ.អ.ប បានធ្វើការរយៈពេលយ៉ាងយូរមកហើយក្នុងការអភិវឌ្ឍ ហើយបើមិនមានការផ្លាស់ប្តូរទេគម្រោងនេះនឹងចាប់ផ្តើមរហូតដល់ឆ្នាំ២០៥០។

ការសម្រេចបានរបស់អង្គភាពនាពេលកន្លងទៅមានដូចជា ការបង្កើតច្បាប់"ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ" ដែលច្បាប់នោះដែរបើកផ្លូវសម្រាប់អោយមានក្រុមប្រឹក្សារាជធានីខេត្ត ស្រុក ខណ្ឌ។ ក្នុងឆ្នាំ២០០២យើងមានក្រុមប្រឹក្សាឃុំ សង្កាត់។ ក្នុងឆ្នាំ២០០៩មានការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ស្រុក ខណ្ឌ។ ពេលនោះរដ្ឋបាលមូលដ្ឋានឈប់គ្រប់គ្រងដោយអាជ្ញាធរមូលដ្ឋានទៀតហើយ ហើយត្រូវមកស្ថិតក្រោមការគ្រប់គ្រងដោយក្រុមប្រឹក្សា វិញ។ ការសម្រេចបានជាលទ្ធផលនៅក្នុងអាណត្តដំបូងនេះ មិនទាន់ចេញជាដុំកំភួនទេ តែអង្គភាពបានចាប់ផ្តើមអោយក្រុមប្រឹក្សាយល់ពីទស្សនវិស័យតាមរយៈកិច្ចប្រជុំជា

ច្រើនហើយគាត់បានតម្រង់ទិសអោយគណៈ អភិបាលទាំងអស់ធ្វើការតាមក្រុមប្រឹក្សាដាក់ចេញ។

គណៈអភិបាលមានន័យថាមានអភិបាលនិងអភិបាលរងហើយក្រុមប្រឹក្សាខុសពីសមាជិកក្រុមប្រឹក្សា ។ ក្រុមប្រឹក្សាមានអំណាចតែសមាជិកក្រុមប្រឹក្សាគ្មានអំណាចទេ។ មានន័យថាការសម្រេចដោយក្រុមប្រឹក្សា ឬបានន័យថាក្នុងអង្គប្រជុំសម្រេចទើបមានអំណាច តែសមាជិកក្រុមប្រឹក្សាម្នាក់ឯងគ្មានអំណាចទេ។ អំណាចពីការប្រជុំទាំងនោះសម្រាប់ធ្វើការដាក់បទបញ្ជាទៅគណៈអភិបាល។

លោកបានបញ្ជាក់បន្ថែមថាមូលហេតុដែលយើងអោយមានក្រុមប្រឹក្សារាជធានី និងក្រុមប្រឹក្សាខេត្ត ស្រុក ខណ្ឌ គឺអោយមានភាពស៊ីជម្រៅផ្នែកនយោបាយនិងរដ្ឋបាល។ ក្នុងផ្នែកនយោបាយគឺចង់អោយភាគី ទាំងអស់ក្លាយទៅជាអ្នកនយោបាយ សម្រាប់ការរៀបចំការបោះឆ្នោត និងដោះស្រាយបញ្ហារបស់ប្រទេស ជាតិតាមរយៈចុងប៊ិចនិងគំនិតវិនិច្ឆ័យ ដែលនៅក្នុងឆ្នាំ១៩៩២ការបង្រួមអោយគណបក្សទាំងអស់ចូលរួមធ្វើ ការបោះឆ្នោតនិងធ្វើការទាំងអស់គ្នា។ និងចំពោះកំណែទម្រង់ផ្នែករដ្ឋបាល ទើបតែនឹងអនុវត្តន៍បានតែ២០% តែប៉ុណ្ណោះ ដោយសារយើងមិនទាន់មានរដ្ឋបាលឯកភាព ហើយនេះជាគោលបំណងដែលអង្គភាពធ្វើកំណែ ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងរយៈ៤០ឆ្នាំខាងមុខនេះ។ រដ្ឋបាលឯកភាពគឺ មានសិទ្ធិអាយដោះ ស្រាយ និងចាត់ចែងគ្រប់ការងារទាំងឡាយនានា លើកលែងតែវិស័យការបរទេសនិងវិស័យយោធា។

### បទបង្ហាញរបស់ លោកស្រី ឌុច ម៉ាលីន មេឃុំយ៉ាង មកពីខេត្តសៀមរាបអំពី"ការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដំណើរការនៃកម្មវិធីវិនិយោគCIP ផែនការអភិវឌ្ឍCDP លទ្ធកម្មឃុំ/សង្កាត់ និងរបៀបដែល យុវជនអាចចូលរួមក្នុងដំណើរការទាំងនោះបាន"។

លោកស្រីឌុច ម៉ាលីន មេឃុំយ៉ាង ស្រុកពួក ខេត្តសៀមរាបបានចែករំលែកបទពិសោធន៍ អំពីការងារ ប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាឃុំរបស់លោកស្រី ដែលមានការពិបាកក្នុងការធ្វើការទំនាក់ទំនង និងធ្វើការពន្យល់ ណែនាំអំពីក្របខ័ណ្ឌច្បាប់មួយចំនួនទៅប្រជាពលរដ្ឋ ។ ក្នុងនាមជាមេឃុំ លោកស្រីបានស្វែងយល់ឃើញថា ក្រុមប្រឹក្សាឃុំរបស់គាត់មានជីវភាពខ្សត់ខ្សោយ ដែលជាមូលហេតុចម្បងដែលធ្វើអោយពួកគាត់ ធ្វើការ មិនបានពេញកម្លាំង និងគ្រប់ជ្រុងជ្រោយ។ លោកស្រីបានបន្តទៀតថាស្មៀនឃុំទទួលបានប្រាក់ខែ មួយខែ ចំនួន១០ម៉ឺនរៀលគឺពិតជាមិនបានគ្រប់គ្រាន់ និងមិនអាចផ្គត់ផ្គង់គ្រួសារបានឡើយ។ ចំពោះកង្វះខាត ធនធានមនុស្សវិញ ក្នុងការបម្រើការងាររដ្ឋបាលក៏ជាបញ្ហាចោទមួយផងដែរ។ ម្យ៉ាងវិញទៀតស្មៀនឃុំ ដោយ សារជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ ម៉ោង១០ឬ១១ គឺគ្មានអ្នកណានៅសាលាឃុំទេ ហើយជាធម្មតាអ្នកប្រចាំ ការនៅឃុំមានតែមេឃុំ ជំទប់១ ជំទប់២ និងស្មៀនតែប៉ុណ្ណោះ។ ពេលល្ងាចជំទប់ទ១និងទី២ មិនសូវមាន វត្តមាននៅសាលាឃុំប៉ុន្មានទេដោយសារជីភាពរបស់ពួកគាត់មានភាពពិបាកខ្លាំង។

លោកស្រីឌុច ម៉ាលីនបានក៏ធ្វើការបង្ហាញអំពីវដ្តនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដែលមាន៥ជំហាន

ដូចជា៖

ជំហានទី១ ៖ សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងថវិកា

ជំហានទី២៖ កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់

ជំហានទី៣៖ សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ជំហានទី៤៖ ការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់

ជំហានទី៥៖ ការវាយតម្លៃអំពីការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ការស្តាប់មតិយោបល់នានារបស់ប្រជាពលរដ្ឋ និងធ្វើការស្រង់មតិពីអ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្តីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់គឺមានសារសំខាន់ណាស់ដើម្បីធ្វើផែនការអភិវឌ្ឍឃុំសង្កាត់ឱ្យស្របនឹងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ។ គ្រប់អ្នកពាក់ព័ន្ធនានាមាន វិស័យឯកជន អង្គការសង្គមស៊ីវិល សមាគម បុគ្គល ហើយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការរៀបចំផែនការនិងថវិកាឃុំ អាចចូលរួមការប្រជុំទាំងឡាយណាដែលរៀបចំឡើងដោយឃុំ។ ហើយលទ្ធផលដែលសម្រេចបានក្នុងជំហានដំបូងគឺធ្វើការប្រមែប្រមូលមតិយោបល់របស់ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាសម្រាប់ធ្វើការកែលំអសេចក្តីព្រាងការក្របខ័ណ្ឌអភិវឌ្ឍនិងថវិកាឃុំ សង្កាត់ដែលបានរៀបចំនៅក្នុងជំហានទីមួយ។

នៅក្នុងជំហានទី២ជាធម្មតាមេឃុំឬចៅសង្កាត់នឹងប្រកាសសេចក្តីជូនដំណឹងសម្រាប់ធ្វើការផ្សព្វផ្សាយពីការពិគ្រោះយោបល់ការអភិវឌ្ឍអោយបានប្រាំថ្ងៃមុនថ្ងៃប្រជុំ ដែលហៅថាសេចក្តីជូនដំណឹងស្តីពីការពិគ្រោះយោបល់ អំពីការអភិវឌ្ឍឃុំ សង្កាត់។ លោកស្រីផ្ទាល់ក៏បានលើកឧទាហរណ៍ក្នុងការធ្វើសេចក្តីជូនដំណឹងរបស់សាលាឃុំយាមជូនដល់សិក្ខាកាមចូលរួមបានស្វែងយល់ពីគំរូនៃសេចក្តីជូនដំណឹងផងដែរ។

ចំពោះសេចក្តីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់ក្នុងជំហានទី៣ដែលបានមកពីការបូកសរុបកិច្ចពិគ្រោះយោបល់ស្តីពី សេចក្តីព្រាងការក្របខ័ណ្ឌអភិវឌ្ឍនិងថវិកាឃុំ សង្កាត់ នឹងត្រូវធ្វើការពិនិត្យឯកភាព និងធ្វើការផ្តល់យោបល់។ ជំហាន៤គឺការអនុម័តផែនការអនុវត្តន៍ឃុំ សង្កាត់គោលបំណងសំខាន់គឺពិនិត្យកែសម្រួលអនុម័តនិងផ្សព្វផ្សាយផែនការអភិវឌ្ឍឃុំ សង្កាត់ក្រោយពីបានទទួលការពិនិត្យផ្តល់យោបល់និងអនុសាសន៍ពីអភិបាលខេត្តមកវិញ ប្រសិនបើអភិបាលខេត្តគ្មានចំណុចកែសម្រួលនោះទេផែនការគឺអាចអនុម័តបានតែម្តង តែប្រសិនបើមានការកែសម្រួលគឺយើងនឹងកែសម្រួលតាមអនុសាសន៍របស់អភិបាលខេត្តដែលបានផ្តល់ជូន។

ជំហានទី៥ទាក់ទងការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់ ចំណុចសំខាន់នៃជំហាននេះគឺការវាយតម្លៃលើប្រសិទ្ធភាពរបស់ផែនការអភិវឌ្ឍឃុំ សង្កាត់នឹងការដកស្រង់យកបទពិសោធន៍នានាជាមូលដ្ឋានក្នុងការគ្រប់គ្រងក្នុងការអនុវត្ត និងការរៀបចំផែនការពេលក្រោយ។

ចំពោះកម្មវិធីវិនិយោគឃុំ សង្កាត់គឺជាផែនការប្រចាំឆ្នាំនៃការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់ដែល

មានគម្រោងអភិវឌ្ឍ និងថវិកាច្បាស់លាស់។ ឃុំ/សង្កាត់កសាងកម្មវិធីវិនិយោគឃុំ/សង្កាត់ជារៀងរាល់ឆ្នាំតាមទម្រង់នៃវដ្តកម្មវិធីវិនិយោគដូចខាងក្រោម៖

ជំហានទី១៖ ការពិនិត្យបញ្ហាឬតម្រូវការជាមួយប្រជាជនឡើងវិញ

ជំហានទី២៖ ការរៀបចំគម្រោងវិនិយោគឃុំសង្កាត់

ជំហានទី៣៖ សិក្ខាសាលាសមាហរណកម្មផែនការវិនិយោគឃុំសង្កាត់

ជំហានទ៤៖ ការអនុម័តកម្មវិធីវិនិយោគឃុំសង្កាត់

ជំហានទី៥៖ ការតាមដានពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគឃុំសង្កាត់

នៅក្នុងឆ្នាំនីមួយៗក្រុមប្រឹក្សាឃុំ សង្កាត់បានទទួលនៅរបាយការណ៍ខ្ទង់ថវិកាដែលគេផ្តល់ជូនតាមឃុំនិមួយៗលើការចំណាយក្នុងផ្នែករដ្ឋបាល និងលើផ្នែកអភិវឌ្ឍ។ ចំពោះផ្នែករដ្ឋបាលឃុំអាចធ្វើការចំណាយទៅលើការឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ជំនួយការឃុំ និងចំណាយរដ្ឋបាលផ្សេងៗ។ ហើយចំណាយរដ្ឋបាលផ្សេងៗក៏អាចយកថវិកាពីកញ្ចប់ថវិកាផ្នែកអភិវឌ្ឍបានចំនួនផងដែរតែមិនអាចលើសពី២០%បានទេ ។ ហើយចំណាយលើផ្នែកអភិវឌ្ឍគឺការចំណាយទាំងឡាយណាទាក់ទងការសាងសង់នានានៅក្នុងឃុំ។

ទម្រង់ការវិនិយោគឃុំ សង្កាត់គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ ខុសគ្នាត្រង់ថាមួយធ្វើប្រាំឆ្នាំ ហើយធ្វើមួយឆ្នាំហើយអនុវត្តន៍តែម្តងនូវគម្រោងដែលបានលើកឡើង។

ទាក់ទងកិច្ចលទ្ធកម្មឃុំ គឺមានន័យថាជាការជ្រើសរើសអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មឬអ្នកផ្គត់ផ្គង់ និងការចុះកិច្ចសន្យាច្បាស់លាស់មួយអំពីការងារដែលពួកគេត្រូវធ្វើ ពេលវេលាដែលត្រូវអនុវត្ត តម្លៃ និងលក្ខខណ្ឌចាំបាច់ផ្សេងៗទៀត។ មេឃុំ ចៅសង្កាត់ត្រូវទទួលខុសត្រូវចំពោះកិច្ចលទ្ធកម្មការងារសាងសង់ លទ្ធកម្មសម្ភារៈ ឬទំនិញ និងលទ្ធកម្មការងារសេវាកម្ម ហើយសមាសភាពរបស់គណៈកម្មការលទ្ធកម្មមានដូចជា៖ មេឃុំឬចៅសង្កាត់ជាប្រធាន សមាជិកក្រុមប្រឹក្សាចំនួន២នាក់ ដែលនឹងត្រូវជ្រើសតាំងដោយក្រុមប្រឹក្សា ជា សមាជិក និងស្មៀនឃុំ សង្កាត់បំពេញតួនាទីជាលេខាធិការឱ្យគណៈកម្មការលទ្ធកម្ម ប៉ុន្តែគាត់មិនអាចបោះឆ្នោតបានឡើយ។

ចំពោះរបៀបដែលយុវជនអាចចូលរួមបានក្នុងកិច្ចលទ្ធកម្មគឺបើកចំហជានិច្ច ហើយវាអាស្រ័យទៅលើឆន្ទៈរបស់ក្រុមយុវជនទាំងអស់ថាតើគាត់មានចិត្តចង់ចូលរួមក្នុងការអភិវឌ្ឍនឹងដែរឬទេ ហើយរាល់ការប្រជុំឃុំ សង្កាត់តែងតែធ្វើដោយចំហដើម្បីអោយមានការចូលរួមនិងមិនមានការលាក់បាំងអ្វីទាំងអស់។

លោកស្រីក៏បានស្តែងពីភាពពិបាកក្នុងការកង្វះខាតផ្នែកធនធានមនុស្សក្នុងការអនុវត្តន៍ការងារប្រចាំថ្ងៃ ជាពិសេសបញ្ហាស្មៀនឃុំមិនអាចទ្រទ្រង់រួចនៅការងារដែលបានដាក់ជូន ដូច្នេះក្នុងនាមលោកស្រីជាមេឃុំត្រូវមានតួនាទីជាសេនាធិការជាប់រហូតដើម្បីធ្វើការទាំងនោះកុំអោយភាពរាំស្ទះ។

## បទបង្ហាញធ្វើឡើងដោយ កញ្ញា ចាន់ សេដ្ឋា មន្ត្រីកម្មវិធី មកពីអង្គការកម្មវិធីអភិវឌ្ឍន៍យុវជន ស្តីពី"បទពិសោធន៍នៃការធ្វើសមាហរ័ណកម្មយុវជនក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន"

កញ្ញាចាន់ សេដ្ឋាបានចាប់ផ្តើមធ្វើបទបង្ហាញដោយការចាក់ខ្សែវីដេអូខ្លីអំពី"កម្មវិធីអ្នកដឹកនាំវ័យក្មេងសម្រាប់ដោះស្រាយសង្គម" ដែលកម្មវិធីនេះធ្វើឡើងដើម្បីទុកឱកាសក្នុងការជជែកពិភាក្សារកផែនការយុទ្ធសាស្ត្រគំនិតថ្មីក្នុងការលើកកម្ពស់ធ្វើយ៉ាងណាអោយសម្រេចបានក្នុងកំណែទម្រង់វិមជ្ឈការ និងសហមជ្ឈការ។

បន្ទាប់ពីការចាក់ខ្សែវីដេអូខ្លីដែលនិយាយពីអភិបាលកិច្ចល្អ និងការពិនិត្យមើលនូវចំណាយចំណូលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ កញ្ញាបានអោយដឹងថា អង្គការកម្មវិធីអភិវឌ្ឍន៍យុវជនបានបង្កើតឡើងតាំងពីឆ្នាំ១៩៩២តែមិនទាន់បានចុះឈ្មោះទេ ហើយការកកើតឡើងនេះគឺកើតឡើងពីបណ្តុំនិស្សិតដែលរៀននៅសាលាសាកលភូមិន្ទភ្នំពេញបានស្វែងយល់ថា យុវជនកម្ពុជាខ្វះខាតខ្លាំងនូវជំនាញការគិតពិចារណា ហើយការជួបគ្នារបស់និស្សិតទាំងនោះយូរៗទៅក៏កើតទៅជាស្ថាប័ន ហើយបានចុះឈ្មោះជាមួយក្រសួងមហាផ្ទៃពេញសិទ្ធិនៅឆ្នាំ១៩៩៩។ ចាប់តាំងពីការបង្កើតឡើងមានយុវជនប្រហែលជា៦ម៉ឺននាក់បានចូលរួមក្នុងកម្មវិធីរបស់អង្គការ ហើយកម្មវិធីព្យាយាម និងបានដាក់គោលដៅស្ត្រីអោយចូលរួមអោយបានច្រើនយ៉ាងហោចណាស់អោយបាន៥០ភាគរយផងដែរ។



*អ្នកចូលរួមមើលខ្សែវីដេអូខ្លីស្តីពី «កម្មវិធីអ្នកដឹកនាំវ័យក្មេងសម្រាប់ដោះស្រាយសង្គម»*
*រូបភាព៖ អង្គការវិទ្យាស្ថានបើកទូលាយ*

ការងារសំខាន់របស់អង្គការៗគឺផ្តោតលើការកសាងសន្តិភាព ការលើកកម្ពស់អភិបាលកិច្ច លើកកម្ពស់បញ្ហាព្រៃឈើ និងបម្រែបម្រួលអាកាសធាតុ រាល់ការប្រជុំទាំងអស់សុទ្ធតែមានការចូលរួមពីយុវជនដើម្បីធ្វើការវិភាគអោយស៊ីជម្រៅ និងរកសក្តានុពលពិតប្រាកដនៃការរៀនសូត្រ ហើយអង្គការក៏មានរៀបចំវេទិកាប្រចាំឆ្នាំផងដែរ។

កម្មវិធីសំខាន់ៗទាំងបួនរបស់អង្គការកម្មវិធីអភិវឌ្ឍន៍យុវជនគឺ ការធ្វើការបណ្តុះបណ្តាល ការផ្តល់សិទ្ធិអំណាច ផ្នែកប្រេងនិងឧស្ម័ន និងការបោះពុម្ពផ្សាយ ហើយអ្វីដែលយើងចង់បានគឺយើងចង់អោយប្រជាពលរដ្ឋសកម្មក្នុងការកសាងសង្គមមួយដែលប្រកបដោយយុត្តិធម៌និងសន្តិភាព និងការអភិវឌ្ឍប្រកបដោយវឌ្ឍនៈភាព។ រាល់ថវិកាដែលអង្គការប្រើប្រាស់គឺធ្វើយ៉ាងណាអោយមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ដូចគម្រោងលើកកម្ពស់យុវជនក្នុងអភិបាលកិច្ចមូលដ្ឋាន រាល់សកម្មភាពទាំងឡាយណាត្រូវគោរពតាមធាតុទាំង

ប្រាំបីរបស់អភិបាលកិច្ចផងដែរ ត្រូវតែមានសមភាព គណនេយ្យភាព តម្លាភាព មានការចូលរួម មានការឆ្លើយតប មានប្រសិទ្ធភាព ប្រសិទ្ធផល និងការចាយវាយតាមគោលដៅ ហើយអោយយុវជនយល់ដឹងពីសកម្មភាព និងអោយពួកគាត់ដើរតួនាទីសំខាន់ៗ។

តាមរយៈការអប់រំ ការពង្រឹងសិទ្ធិអំណាច យុវជនអាចយល់ដឹងច្បាស់អ្វីជាឫសគល់ពិតប្រាកដ នៃបញ្ហា ទើបយុវជនអាចដោះស្រាយបញ្ហាទាំងនោះបាន។ ហេតុដូចនេះរាល់គម្រោងរបស់អង្គការកម្មវិធីអភិវឌ្ឍន៍យុវជន ព្យាយាមអោយយុវជនរកមូលហេតុនៃបញ្ហា ហើយធ្វើការឆ្លុះបញ្ចាំងធាតុផ្សំពាក់ព័ន្ធនានា។

កញ្ញាបានបន្តថាការអប់រំគឺជានយោបាយ ព្រោះអ្វីៗដែលមានគឺកើតពីនយោបាយទាំងអស់។ ប៉ុន្តែយុវជនហាក់ដូចជាមានអារម្មណ៍មិនសុខស្រួលទាំងផ្លូវកាយនិងផ្លូវចិត្តក្នុងការនិយាយបញ្ហានយោបាយ តែតាមធាតុពិតនយោបាយគឺជាពាក្យដែលសាមញ្ញបំផុតដែលមនុស្សគ្រប់រូបតែងតែពាក់ព័ន្ធខ្លាំងបំផុតព្រោះអោយតែមានដង្ហើម។ ការហូបទឹក ញ៉ាំអាហារ ការប្រើប្រាស់សម្ភារៈ គឺត្រូវតម្រូវបង់ពន្ធអោយរដ្ឋជានិច្ច។ ដូច្នោះយុវជនត្រូវមានចម្ងល់ថាតើថវិកាបង់ពន្ធអោយរដ្ឋនោះទៅណាអស់ និងប្រើទៅ លើអ្វីខ្លះ ការមានជីវិតគឺពាក់ព័ន្ធនឹងនយោបាយទាំងអស់ដូច្នេះពាក្យនឹងប្រែមកជាពាក្យមួយដ៏សាមញ្ញបំផុត ហើយគួរជំរុញអោយមានការចូលរួមពិភាក្សាអោយបានច្រើន។

តាមមតិកញ្ញាការអភិវឌ្ឍមួយជំហានទៅមួយជំហានមានការផ្លាស់ប្តូរបន្តិចម្តងៗ រហូតដល់ប្រជាពលរដ្ឋអាចយល់ដឹងនិងអាចចូលរួមបាន។ យើងគួរតែលើកទឹកចិត្តយុវជនអោយគូសបង្ហាញនូវទស្សនវិស័យរបស់ពួកគាត់ ថា តើភាពប្រាកដរបស់យុវជនចង់បានអ្វីខ្លះ? ក្នុងប្រព័ន្ធអប់រំបានព្យាយាមកែប្រែអោយកាន់តែល្អនិងលើកកម្ពស់ច្រើន តែកង្វះខាតតិចតួចចដែលនៅមិនទាន់ជ្រួតជ្រាបនៅឡើយ អញ្ចឹងមានតែការអប់រំក្រៅប្រព័ន្ធដែលនឹងជួយអោយយុវជនចេះវិភាគពីបញ្ហាសង្គមដោយគ្មានគំនាបសង្កត់ ដើម្បីរកគំនិតថ្មីប្រឌិត និងអនុវត្តន៍។ ការបង្ហាញអោយយុវជនឃើញសហគមន៍ ការសិក្សាជាក់ស្តែងនឹងបង្កើនឆន្ទៈអោយមានការចូលរួមកាន់តែច្រើន ប្រសិនបើគាត់មិនបានចុះផ្ទាល់ពួកគាត់នឹងឃើញរូបភាពមួយដែលអាចដុតបេះដូងគាត់គ្រប់គ្រាន់ ពីព្រោះបេះដូងអ្នកអភិវឌ្ឍត្រូវមានភាពទូលាយ និងរឹងមាំហ៊ានទុកនូវបញ្ហានានារបស់សង្គមជាច្រើន។ ការចូលរួមរបស់ពួកគាត់ក្នុងកម្មវិធីនឹងកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ទំនាស់ដីធ្លីសម្រស់បៃតង វេទិកាផ្សេងៗ ជាពិសេសទាក់ទងចំណាយចំណូលទាក់ទង់ការប្រើប្រេងឧស្ម័នដែលពីមុនគាត់មិនសូវបានដឹងសោះ។

នៅក្នុងគម្រោងរបស់កញ្ញាបានធ្វើឡើងតាំងពីពាក់កណ្តាលឆ្នាំ២០០៩ ដែលគម្រោងនោះមានឈ្មោះថាកម្មវិធីពង្រឹងសង្គមស៊ីវិលដែលលើកកម្ពស់គណនេយ្យភាព ដែលពេលនោះគ្រាន់តែជាគម្រោងសាកល្បងតែប៉ុណ្ណោះ។ ហើយចាប់ពីឆ្នាំ២០១១គម្រោងរបស់ធនាគារពិភពលោក អំពីទម្រង់អភិបាលកិច្ចល្អមូលដ្ឋានបានផ្តល់ជំនួយដល់ក្រសួងមហាផ្ទៃមួយចំនួនធំ និងមូលនិធិអាស៊ីមួយចំនួនដើម្បីអោយធ្វើសកម្មភាពការងារ


ប្រអប់សំបុត្រលេខ ១៥៥២ ទូរស័ព្ទ(៨៥៥-២៣) ២២៤ ៨២១ អ៊ីមែល៖ openinstitute@open.org.kh វិប សាយ៖ http://open.org.kh

ពាក់ព័ន្ធ។ ដែលមានគោលបំណងធ្វើជាស្ពានចម្លងសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ ជាលទ្ធផលអង្គការបានធ្វើចំនួន៤ជំនាន់ ហើយអ្នកចូលរួមមានចំនួនជាង៦០នាក់ ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលរយៈពេល១ឆ្នាំ។ ធ្វើការកសាងសមត្ថភាពនិងពង្រឹងការទំនាក់ទំនង តាមរយៈទស្សនកិច្ចសិក្សាជាមួយក្រុមប្រឹក្សាឃុំនៅ ខេត្តសៀមរាប បាត់ដំបង កំពង់ឆ្នាំង ស្វាយរៀង កំពង់ចាម ដើម្បីរៀនសូត្រពីការងារភូមិនិងពីគម្រោងដែលបានជោគជ័យផងដែរ ការចុះអនុវត្តន៍ផ្ទាល់ទាំងយុវជននិងក្រុមប្រឹក្សាឃុំ ក្នុងរយៈពេលបីថ្ងៃនោះបានធ្វើអោយគាត់កាន់តែស្និតស្នាល និងហ៊ានជជែកជាមួយគ្នាថែមទៀត គម្រោងក៏មានការរៀបចំ ការផ្លាស់ផ្តូររវាងឃុំនិងឃុំដើម្បីផ្សារភ្ជាប់បណ្តាញផងដែរ។ តួលេខដែលយើងមានគឺ៦៥នាក់ជានិស្សិត ជាង៩០០០នាក់ជាអ្នកភូមិ។ តាមការអង្កេតផ្ទាល់របស់កញ្ញានៅក្នុងគម្រោងផ្ទាល់ឃើញថា យុវជនមានការចាប់អារម្មណច្រើន និងមានការផ្លាស់ប្តូរឥរិយាបថមួយចំនួនពីការមិនសូវចង់ចូលរួមសកម្ម បែរជាស្វះស្វែងក្នុងរៀបចំក្រុមខ្លួនឯងដើម្បីជួបជុំពិភាក្សាគ្នារាល់ថ្ងៃសម្រាប់ចែកព័ត៌មាននិងអាចជួបជុំគ្នាទៀតក្រោយគម្រោងចប់ ហើយនេះគឺជាការផ្តួចផ្តើមឡើងដោយក្រុមគាត់ផ្ទាល់។

នៅក្នុងនោះដែរកញ្ញាក៏បានលើកយកករណីសិក្សាពីភូមិមួយដែលមានបញ្ហា ដោយសារមានក្រុមហ៊ុនបានមកធ្វើកសិដ្ឋាននៅកណ្តាលភូមិហើយវាជះក្លិនមិនល្អ ដែលវាបានធ្វើអោយប៉ះពាល់ដល់សុខភាពនិងជីវិតរស់នៅ។ ដំណោះស្រាយអ្នកភូមិបានប្រើប្រាស់យន្តការប្រអប់ និងការប្រជុំឃុំប្រចាំខែដើម្បីលើកយកបញ្ហានេះមកដោះស្រាយជាមួយឃុំ ដែលការងារទាំងអស់នេះពីមុនគាត់មិនដឹងពីរបៀបនិងហ៊ានធ្វើការតស៊ូមតិនោះទេ។ ប្រអប់គណនេយ្យភាពតាមភូមិគឺមានទាំងអស់ចំនួន១៦៣៣ តែការជ្រួតជ្រាបក្នុងការប្រើប្រាស់ប្រអប់នៅមិនទាន់បានល្អ និងការយល់ដឹងនៅមានកម្រិត យើងបានធ្វើការផ្សព្វផ្សាយពីប្រអប់ និងអំពីយន្តការការប្រើប្រាស់ប្រអប់សម្រាប់ជាឧបករណ៍របស់គាត់សម្រាប់ពាំនាំសម្លេងរបស់ពួកគាត់ទៅដល់ខាងឃុំ។

គម្រោងលើកំណែទម្រង់នេះ គួរតែត្រូវធ្វើទៅមុខទៀតពីព្រោះដោយសារប្រជាពលរដ្ឋនិងអាជ្ញាធរមានការយល់ដឹងនៅមានកម្រិតនៅឡើយ។ បញ្ហាលំបាកមួយទៀតគឺគោលនយោបាយរបស់គណបក្ស ដែលពួកគាត់មានតួនាទីអភិវឌ្ឍផងនិងគណបក្សផង ហើយសេរីភាពក្នុងការនិយាយក៏មានការពិបាកក្នុងការនិយាយផងដែរ ហើយព័ត៌មានដែលចេញពីឃុំទៅប្រជាពលរដ្ឋ និងពីប្រជាពលរដ្ឋទៅភូមិវិញក៏ពិបាក។ ហើយការពិបាកក្នុងការចាប់ផ្តើមដំបូងបំផុតក្នុងឆ្នាំ២០០៩។

កញ្ញាបានកត់សម្គាល់ថាមានស្ថាប័ន និងគណបក្សជាច្រើនបានកំពុងចាប់អារម្មណនឹងធ្វើការជាមួយយុវជន និងចង់អោយពួកគេចូលរួមគ្រប់សកម្មភាពអភិវឌ្ឍន៍របស់ពួកគាត់។ កាលពីឆ្នាំ២០១១ ថ្ងៃទី២៤ ខែ៦គឺគោលនយោបាយជាតិស្តីពីយុវជនត្រូវបានអនុម័ត ហើយនៅក្នុងគោលនយោបាយនោះមាន១២ ចំណុចសំខាន់។ ចំណុចទី៦និយាយសំខាន់ដែរនោះគឺការចូលរួមរបស់យុវជន ដែលនៅក្នុងនោះគោល

នយោបាយនោះបានថែងថាអោយគាត់ចូលរួមជាមួយនឹងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ការបង្កើតបរិយាកាសអោយយុវជនបានដឹង និងបានយល់ពិតជាមានភាពសំខាន់បំផុតហើយយើងបានអញ្ជើញពួកគាត់អោយបានជួបគ្រប់គណបក្សនយោបាយដើម្បីស្តាប់នូវគោលនយោបាយនិមួយៗ ហើយថាតើគណបក្សទាំងនោះធ្វើអ្វីខ្លះ ពីព្រោះការងារឯកសារគោលមួយចំនួនមានភាពពិបាកយល់មែនទែន ដូច្នេះមានតែការជួបផ្ទាល់ដើម្បីបរិយាយអោយពួកគាត់បានយល់។ តាមរយៈបទពិសោធន៍របស់កញ្ញក្នុងរយៈពេល៦ឆ្នាំនេះបានស្វែងយល់ថាមូលហេតុនៃការមិនចូលរួមរបស់យុវជនគឺយុវជនមិនបានដឹងនិងមិនយល់។

កញ្ញបានសង្កត់ធ្ងន់ថាការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យគឺមានភាពចាំបាច់យ៉ាងសំខាន់ និងកញ្ញបានកោតសរសើរអំពីឆន្ទៈរបស់យុវជននាពេលបច្ចុប្បន្នក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសង្គម និងសហគមន៍របស់ពួកគេ។ កញ្ញបានសង្ឃឹមទុកថាយុវជននឹងមិនត្រូវបានគេចាត់ទុកថាជាបញ្ហារបស់សង្គមទៀតឡើយ។ កញ្ញបានបន្តទៀតថាពួកយើងគួរតែជួយនិងលើកទឹកចិត្តយុវជនក្មេងអោយប្រើពេលទំនេររបស់ពួកគេអោយមានប្រយោជន៍ និងផ្តល់សិទ្ធអំណាចអោយពួកគេ។

ការពិភាក្សាទៅលើសំណួរដូចខាងក្រោម៖

១ ហេតុអ្វីប្រជាពលរដ្ឋដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអភិបាលកិច្ចល្អ?

២ តើយុវជនមានតួនាទីយ៉ាងដូចម្តេចខ្លះដើម្បីរួមចំណែកក្នុងអភិបាលកិច្ចល្អក្នុងសហគមន៍របស់ពួកគេ?

៣ តើយុវជនអាចចូលរួមក្នុងសកម្មភាពនានារបស់ឃុំ សង្កាត់បានយ៉ាងដូចម្តេច?

៤ តើយុវជនទទួលបានផលប្រយោជន៍អ្វីខ្លះពីការចូលរួមក្នុងការងារសហគមន៍ជាពិសេសការងារអភិបាលកិច្ចឃុំ សង្កាត់?

៥ តើមានយុទ្ធសាស្រ្តអ្វីខ្លះដែលអាចលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងពង្រឹងកិច្ចការមូលដ្ឋាននិងអភិបាលកិច្ចល្អ?

បន្ទាប់ពីបទបង្ហាញរបស់កញ្ញ ចាន់ សេដ្ឋា រួចមកវេទិកាពិភាក្សាបានចាប់ផ្តើមដោយលោកស្រី ជឹម ម៉ាណាវី នាយិកាប្រតិបត្តិនៃអង្គការវិទ្យាស្ថានបើកទូលាយជាអ្នកសម្របសម្រួលកិច្ចពិភាក្សា។ ដោយពេលវេលាខ្លី អង្គប្រជុំបានចាប់ផ្តើមការពិភាក្សាទៅលើទាំងប្រាំសំនួរតែម្តងក្នុងកំឡុងពេលពិភាក្សា។

លោកសៀម វត្ថារិទ្ធិ ជា ក្រុមមិត្តអប់រំមិត្តរបស់សមាគមអភិវឌ្ឍសុខភាពប្រជាជនបានមានមតិថា បើនិយាយអំពីអភិបាលកិច្ចល្អគឺចង់និយាយពីតួអង្គបួន តាមដែលលោកបានដឹងមានដូចជា ប្រជាពលរដ្ឋ ក្រុមអភិបាល សង្គមស៊ីវិល និងវិស័យឯកជន។ តួអង្គដែលសំខាន់ជាងគេគឺប្រជាពលរដ្ឋក្នុងការបង្កើតតអោយមានអភិបាលកិច្ចល្អ ព្រោះអភិបាលកិច្ចល្អនេះបង្កើតឡើងសម្រាប់ប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ ពីព្រោះថាអភិបាលកិច្ចល្អនេះគឺធ្វើសម្រាប់ឃុំ សង្កាត់ក៏ដូចកិច្ចការងាររបស់ខ្លួនហើយអ្នកដែលទទួលផលផ្ទាល់គឺប្រជា

ពលរដ្ឋខ្លួនឯងផ្ទាល់។ ប្រជាពលរដ្ឋនឹងដើរតួសំខាន់មែនទែន ប្រសិនបើគាត់មិនបានចូលរួមក្នុងអភិបាលកិច្ចល្អនេះទេ ។ អាចធ្វើអោយអ្នកដឹកនាំគាត់ ដឹកនាំដោយគ្មានអភិបាលកិច្ចល្អ ព្រោះគាត់ជាអ្នកតាមដាននិងទទួលផលប្រយោជន៍នេះ។

លោកនៅ វឌ្ឍី ជា យុវជនតំណាងមកពីអង្គការកម្មវិធីអភិវឌ្ឍធនធានយុវជនបានមានយោបល់ថា ដើម្បីអោយមានអភិបាលកិច្ចល្អ គឺត្រូវមានការចូលរួមពីប្រជាពលរដ្ឋដែលមានសារសំខាន់មែនទែន។ ប្រជាពលរដ្ឋគឺចូលរួមយ៉ាងសកម្ម ក្នុងន័យថាដើម្បីអោយមានអភិបាលកិច្ចល្អត្រូវមានគណនេយ្យភាព ដែលទាមទារអោយមានការចូលរួមពីប្រជាពលរដ្ឋ យ៉ាងសកម្មនិងអាជ្ញាធរដែលមានសមត្ថភាព។ ប្រជាពលរដ្ឋដែលសកម្មគឺជាប្រជាពលរដ្ឋដែលចេះស្វែងរកព័ត៌មានចង់ដឹងពីតម្រូវការរបស់គាត់ ដើម្បីទទួលបានថាគាត់មានសិទ្ធិប៉ុន្មាន និងមានតួនាទីយ៉ាងណានៅក្នុងសហគមន៍របស់គាត់នោះ ព្រោះគាត់ជាអ្នកទទួលផ្ទាល់។

លោកស្រីជឹម ម៉ាណាវីបានបញ្ជាក់បន្ថែមថា ការចូលរួមរបស់ប្រជាពលរដ្ឋមានសារសំខាន់ណាស់ ដើម្បីចូលរួមក្នុងដំណើរការអភិបាលកិច្ចល្អ ពីព្រោះពួកគាត់ជាអ្នកទទួលផលប្រយោជន៍ផ្ទាល់ពីអភិបាលកិច្ចល្អ ហើយដំណើរការនឹងមិនរលូតទៅមុខបើគ្មានការចូលរួម។ លោកស្រីក៏បានព្យាយាមបំផុសអោយសិក្ខាកាមមានមតិទៅលើសំនួរទាំង៥ដើម្បីប្រមូលផ្តុំការគិត។ លោកស្រីបានអោយសិក្ខាកាមចាត់ទុកថានេះជាវេទិកាមួយដែលយើងអាចនិយាយអ្វីក៏បានហើយសំណូមពរអោយសិក្ខាកាមកុំអោយមានការខ្លាចរអាក្នុងការបញ្ចេញមតិរបស់យើង។

កញ្ញាគឹម សុភ័ក្រជានិស្សិតនៅសាលាច្បាប់និងជាមិត្តអប់រំមិត្តមកពីអង្គការអប់រំសុខភាពប្រជាជន មានទស្សនៈថា នាងខ្ញុំជាយុវជនគួរមានតួនាទី ស្វែងរកព័ត៌មានអំពីឃុំ សង្កាត់ដែលគាត់កំពុងរស់នៅ ហើយនៅពេលដែលពួកគាត់ទទួលបាននូវព័ត៌មានទាំងនោះគាត់គួរតែចែករំលែកព័ត៌មានដែលទទួលបានទាំងនោះទៅប្រជាពលរដ្ឋនៅក្នុងតំបន់ ហើយពួកគាត់គួរតែព្យាយាមចូលរួមសកម្មភាពផ្សេងៗដូចជាការបោះឆ្នោតខាងមុខនេះ ឬសុខភាពអនាម័យ ឬក៏យល់ពីតម្លៃនៃសន្លឹកឆ្នោតនិមួយៗ។

លោកឈៀង ចាន់ហេង មកពីអង្គការយុវជនខ្មែរនិងការអភិវឌ្ឍសង្គមបានមានប្រសាសន៍ថា ការពិតទៅយើងបានយល់ទាំងអស់គ្នាពីតួនាទីរបស់យុវជន ដែលពួកគេជាសសរទ្រូងរបស់ប្រទេសជាតិ។ លោកគិតថាយុវជនបានដឹងច្បាស់ពីតួនាទីរបស់ខ្លួនឯងនិងឃើញថាពួកគេពាក់ព័ន្ធនឹងរឿងនេះ។ តាមការបង្ហាញរបស់លោកតួនាទីទី១របស់យុវជនគឺត្រូវពង្រឹងសមត្ថភាពខ្លួនឯងអោយបានរឹងមាំជាមុនសិន មានតួនាទីជាគំរូភាពក្នុងការដឹកនាំឬ



*លោកឈៀង ចាន់ហេង តំណាងយុវជនខ្មែរ និងការអភិវឌ្ឍសង្គម*
*រូបភាព៖ អង្គការវិទ្យាស្ថានបើកទូលាយ*

គំរូភាពល្អក្នុងសង្គម ធ្វើដូចម្ដេចអោយមានការលេចធ្លោ គឺត្រូវធ្វើយ៉ាងណាអោយខ្លួនឯងនឹងស្វែងយល់នឹងមានការចេះដឹងនូវចំណេះដឹងពាក់ព័ន្ធ។ ហើយពួកគេគួរមានការចូលរួមល្អជាមួយរដ្ឋាភិបាល អង្គការសាលារៀន និងការងារឃុំ សង្កាត់។ ការរស់នៅក្នុងសហគមន៍យើងត្រូវចូលរួមតាមដានព័ត៌មាន និងទទួលយកព័ត៌មាននៅក្នុងសហគមន៍របស់ខ្លួនឯង ហើយចូលរួមជាមួយអាជ្ញាធរក្នុងដោះស្រាយនូវបញ្ហាដែលមាននៅក្នុងភូមិ ធ្វើការចាប់ដៃជាមួយគាត់ដោះស្រាយជាមួយគាត់។ តួនាទីទី២យុវជនមិនត្រូវប៉ៅឡែ មិនបំពុលសង្គម គ្រឿងញៀន និងរឿងបងធំបងតូច ដែលបង្កជាបញ្ហាមួយសម្រាប់រដ្ឋាភិបាលដោះស្រាយ ដូច្នេះយុវជនត្រូវចេះណែនាំអោយមិត្តភក្ត្ររបស់គាត់អោយចេះណែនាំអោយមកកាន់ផ្លូវល្អវិញ និងចូលរួមក្នុងការងារសង្គម។ ជាពិសេសយុវជនត្រូវតែចូលរួមលើការងារមួយចំនួនមិនថាជាថវិកាឬកម្លាំងយុវជនអាចជួយកសាងផ្លូវថ្នល់ និងការធ្វើអោយប្រសើរនូវការងារទាំងឡាយណាក្នុងការកសាង ជាពិសេសក្នុងការងារអភិបាលកិច្ចល្អ។ ការចូលរួមរបស់ពួកគាត់នឹងធ្វើអោយមានការរីកចំរើននិងការអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់គាត់និងសហគមន៍របស់គាត់។

លោកឃួន សុផុន ជាក្រុមប្រឹក្សាសង្កាត់រាជធានីភ្នំពេញ ចៅសង្កាត់ទួលទំពូងទី២ ខណ្ឌចំការមនបានមានប្រសាសន៍ថា ប្រជាពលរដ្ឋទាំងពីរភេទគឺជាកោសិការបស់សង្គម និងទាមទារអោយមានការអភិវឌ្ឍល្អ ដើម្បីធ្វើការស្ដាហេដ្ឋារចនាសម្ពន្ធ និងការងារផ្សេងៗក្នុងអភិបាលកិច្ចល្អ។ ក្នុងកំណែទម្រង់រដ្ឋបាលរយៈពេលវែងរហូត៤០ឆ្នាំដូច្នេះមានតែយុវជនទេដែលនឹងស្នងតំណែងនេះបន្ត ក្នុងការអភិវឌ្ឍរបស់អភិបាលកិច្ចល្អ និងឈានទៅរកប្រជាធិបតេយ្យពិតប្រាកដ។ ដូច្នេះយុវជនគួរតែពង្រឹងដូចដែលសិក្ខាកាមមុនៗបានចែករំលែក ជាពិសេសការពង្រឹងចំណេះដឹងទូទៅ ពង្រឹងសមត្ថភាពបច្ចេកទេសជំនាញ ពង្រឹងនិងពង្រីកទំនាក់ទំនងល្អជាមួយគ្រប់ស្ថាប័ន និងមានទស្សនៈទូលាយក្នុងការចែករំលែកព័ត៌មានទាំងឡាយណាដែលទទួលបានត្រូវចែកគ្នាទៅវិញទៅមក ដើម្បីជួយស្ដារប្រទេសជាតិទាំងអស់គ្នា និងមានភាពជឿនលឿនតាមសកលភាវូបនីយកម្មតាមសកលលោក។ ដូច្នេះយុវជនត្រូវតាមអោយជាប់ និងព្យាយាមអនុវត្តន៍តាមសម័យកាលនិមួយៗ។

លោកសាក់ សំកុល ក្រុមប្រឹក្សាសង្កាត់ទួលស្វាយព្រៃទី១ខណ្ឌចំការមនបានមានប្រសាសន៍ថា ទាក់ទងបញ្ហាសន្តិសុខយុវជនគួរចូលរួមធ្វើការទប់ស្កាត់ សហការ និងរាយការណ៍ដល់សមត្ថកិច្ច និងអាជ្ញាធរដើម្បីធានាសុវត្ថិភាព ពីព្រោះយុវជនជាកម្លាំងស្នូលដើម្បីធ្វើការទាំងនោះ។

កញ្ញាចាន់ សេដ្ឋា បានលើកយកបញ្ហាពីរចំណុចដែលជាធម្មតាតែងតែលឺពីប្រជាជនថា យុវជនតែងតែត្រូវបានចាត់ទុកជាបញ្ហា ហើយយុវជនតែងតែត្រូវបានគេទម្លាក់ទោសកំហុសទៅលើ តាមការពិតយុវជនក៏ជាមនុស្សមួយរូបដែលត្រូវការយកចិត្ត ទុកដាក់ ត្រូវការពេលវេលាដើម្បីធ្វើសិក្សាលូតលាស់ដើម្បីធ្វើជាមនុស្សពេញវ័យ។ យុវជនជាច្រើនមិនបានលើកកម្ពស់អោយមានការចូលរួម មានអ្វីដែលជារបស់ខ្លួនឯងទេ និងមិន

ត្រូវបានចាប់អារម្មណ៍ឡើយ។ យើងគួរតែលើកទឹកចិត្តយុវជនអោយមានការចូលរួមច្រើនដែរ ហើយសហគមន៍គួរទុកចិត្តនិងអោយតម្លៃ។ ចំណុចមួយទៀតដែលសំខាន់គឺការមិនលើកទឹកចិត្ត និងមិនអោយតម្លៃក្នុងការបញ្ចេញមតិដោយសារពួកគេមិនបទពិសោធន៍ដូច្នេះយុវជននិងមនុស្សពេញវ័យគួរតែបន្ទន់ឥរិយាបទទៅគ្នាទៅវិញទៅមក ដើម្បីអោយមានការដោះដូរមតិទៅវិញទៅមក។

លោកស្រស់ ណូ យុវជនមកពីសមាគមអភិវឌ្ឍសុខភាពប្រជាជនបានមានមតិថា យុវជនគួរយល់ដឹងបន្ថែមពីអត្ថន័យ និងធាតុរបស់អភិបាលកិច្ចល្អ ដូចជាពាក្យប្រជាធិបតេយ្យមានលក្ខណៈរសើប និងមិនត្រូវបានលើកទឹកចិត្តក៏ដូចជាមានភាពភ័យខ្លាចក្នុងការនិយាយ។ យុវជនតែងតែគិតថាការធ្វើអោយមានប្រជាធិបតេយ្យគឺជាតួនាទីរបស់រដ្ឋាភិបាលនិងមនុស្សដែលមានវ័យចំណាស់ ហើយយុវជនខ្លួនឯងមិនសូវបានចូលរួមទេ។ យុវជនក្នុងការបោះឆ្នោតគឺមានតួនាទីសំខាន់ណាស់ ដូច្នេះពួកគេគួរតែស្វែងរកព័ត៌មានទាំងឡាយទាក់ទងនឹងការបោះឆ្នោត។

លោកសុខ ហេង យុវជនមកពីសមាគមអភិវឌ្ឍសុខភាពប្រជាជនបានឆ្លើយតបថា មានប្រយោជន៍ធំៗពីរដែលយុវជនទទួលបានពីការចូលរួមក្នុងការងារមូលដ្ឋានជាពិសេសការងារអភិបាលកិច្ចល្អ។ ទីមួយសម្រាប់បុគ្គល គឺពួកគាត់នឹងទទួលបានចំណេះដឹងទាក់ទងអភិបាលកិច្ចល្អ បទពិសោធន៍នៅលើការងារជាក់ស្តែង ព័ត៌មាននានាទាក់ទងឃុំ សង្កាត់ ជំនាញក្នុងធ្វើការងារទាំងនោះដោយខ្លួនឯង និងទីពីរសម្រាប់សហគមន៍ ដែលមានពលរដ្ឋសកម្មដែលជាធនធានមួយដ៏សំខាន់ និងកសាងរូបវន្តនានាទាក់ទងការកសាងផ្លូវថ្នល់ និងសំណង់អាគារផ្សេងៗ។



*កញ្ញា លី ម៉ី មកពីសមាគមអភិវឌ្ឍសុខភាពប្រជាជន*
*រូបភាព៖ អង្គការវិទ្យាស្ថានបើកទូលាយ*

កញ្ញាលី ម៉ី យុវនារី មកពីសមាគមអភិវឌ្ឍសុខភាពប្រជាជនមានយោបល់បន្ថែមថា យុវជនអាចចូលរួមដោយសេរីនិងការស្ម័គ្រចិត្ត ដូចជាការចូលរួមប្រជុំ និងទទួលយកព័ត៌មាននានា ហើយយកចំណេះដឹងដែលទទួលបាននោះធ្វើការផ្សព្វផ្សាយចំណេះដឹងទាំងនោះទៅ
សហគមន៍របស់ពួកគាត់។

លោកពេជ្យ ចំណាស់ បុគ្គលិកមកពីវិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយបានមានប្រសាសន៍ថា យុទ្ធសាស្ត្រដើម្បីអោយយុវជនចូលរួមមានដូចជាការបង្កើតវេទិកាពិភាក្សា កម្មវិធីមិត្តអប់រំមិត្ត លើកទឹកចិត្តអោយយុវជនចូលរួមក្នុងការអភិវឌ្ឍឃុំ សង្កាត់។ ធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយនានា លើកទឹកចិត្តផ្ទាល់ ការចាក់ផ្សាយកម្មវិធីយុវជនដែលជាគំរូដោយបង្ហាញការងារសំខាន់ៗរបស់យុវជនក្នុងអភិវឌ្ឍន៍។ សំណូមពរអោយយុវជនអាចធ្វើការស្ម័គ្រចិត្តអនុវត្តផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ឬការដាក់ឈ្មោះអោយយុវជនអោយចូលរួមឈរឈ្មោះក្នុងការបោះឆ្នោត។


ប្រអប់សំបុត្រលេខ ១៥៥២ ទូរស័ព្ទ(៨៥៥-២៣) ២២៤ ៨២១ អ៊ីមែល៖ openinstitute@open.org.kh វិប សាយ៖ http://open.org.kh

## ៧. លទ្ធផលនៃវេទិកាពិភាក្សា

ចុងបញ្ចប់នៃវេទិកាពិភាក្សា លោកស្រីជឹម ម៉ាណាវី នាយិកាអង្គការវិទ្យាស្ថានបើកទូលាយ និងជាអ្នកសម្របសម្រួលវេទិកាពិភាក្សាបានបូកសរុបលទ្ធផលនិងផ្ដល់អនុសាសន៍នៃកិច្ចពិភាក្សាដូចខាងក្រោម៖

- សំនួរទី១៖ ហេតុអ្វីប្រជាពលរដ្ឋដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអភិបាលកិច្ចល្អ?
  តួនាទីប្រជាពលរដ្ឋក្នុងអភិបាលកិច្ចល្អគួរតែមាន៨ចំណុចសំខាន់ៗមានដូចជា៖ ការចូលរួមពេញលេញ ការផ្សព្វផ្សាយទូទៅ តួនាទីច្បាប់ តម្លាភាព សមភាព ប្រសិទ្ធផលនិងប្រសិទ្ធភាព គណនេយ្យភាព និងការទទួលខុសត្រូវ។ ប្រជាពលរដ្ឋគួរតែមានតួនាទីសកម្ម និងយល់អំពីតួនាទីរបស់ពួកគេដើម្បីធានាបានថាការងារនេះនឹងប្រព្រឹត្តទៅមុខដោយរលូន។
- សំនួរទី២៖តើយុវជនមានតួនាទីយ៉ាងដូចម្ដេចខ្លះដើម្បីរួមចំណែកក្នុងអភិបាលកិច្ចល្អក្នុងសហគមន៍របស់ពួកគេ?
  យុវជនគួរតែស្គាល់ពីតម្លៃរបស់ខ្លួនឯង និងកម្រិតនៃការចូលរួមរបស់យុវជននៅក្នុងសង្គមសម្រាប់ជាតិ។ យុវជនមានតួនាទីសំខាន់ផ្សេងៗ ដូចជាចែករំលែកព័ត៌មាន អភិវឌ្ឍសមត្ថភាពខ្លួនឯង ស្វះស្វែងទទួលយកព័ត៌មាន និងធ្វើជាគំរូល្អមួយដល់សង្គម។ ជាពិសេស ត្រូវចេះសហការជាមួយអាជ្ញាធរក្នុងតំបន់ដើម្បីធានាសុវត្ថិភាពសន្តិសុខរបស់សហគមន៍។ ក្នុងកិច្ចពិភាក្សាក៏បានសម្ដែងនៅការព្រួយបារម្ភផងដែរថាយុវជនមួយចំនួនតូចមានការពាក់ព័ន្ធជាមួយគ្រឿងញៀន និងគ្រឿងស្រវឹង និងមួយចំនួនចំណាយពេលវេលាជាច្រើនជាមួយវីដេអូហ្គេម។
- សំនួរទី៣៖ តើយុវជនអាចចូលរួមក្នុងសកម្មភាពនានារបស់ឃុំ សង្កាត់បានយ៉ាងដូចម្ដេច?
  យុវជនគួរតែចូលរួមអង្កេតនូវការលូតលាស់និងការវិវឌ្ឍនៃការអភិវឌ្ឍថ្នាក់ក្រោម។ ពួកគេគួរតែមានតួនាទីសកម្មក្នុងថ្នាក់តំបន់ដើម្បីចូលរួមតាមដានការចាយវាយរបស់ផែនការហិរញ្ញវត្ថុរបស់គម្រោងអភិវឌ្ឍឃុំ/សង្កាត់។ មូលនិធិរបស់ការអភិវឌ្ឍគួរតែមានការចូលរួមរបស់យុវជន។
- សំនួរទី៤៖តើយុវជនទទួលបានផលប្រយោជន៍អ្វីខ្លះពីការចូលរួមក្នុងការងារសហគមន៍ជាពិសេសការងារអភិបាលកិច្ចឃុំ សង្កាត់?
  យុវជន និងមនុស្សវ័យចំណាស់អាចផ្ដល់ផលប្រយោជន៍អោយគ្នាទៅវិញទៅមក តាមរយៈចំណេះដឹងនិងសមត្ថភាព។ ការចូលរួមរបស់យុវជននឹងជំរុញលើកកម្ពស់អភិបាលកិច្ចល្អ។ ការជួយរបស់យុវជនមានអត្ថន័យយ៉ាងសំខាន់សម្រាប់ផ្ដល់អោយការងារឃុំ សង្កាត់កាន់តែមានមុខងារងាយស្រួលនិងយ៉ាងមានប្រសិទ្ធភាព។ ជាពិសេសជាងនេះទៅទៀតការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍរបស់ឃុំ សង្កាត់ ដែលនឹងជួយកាត់បន្ថយនូវការចាត់ទុកយុវជនគឺជាបញ្ហារបស់សង្គម។ យុវជននឹងផ្ដល់នូវគំនិតថ្មីៗនិងទស្សនៈល្អៗ។ យុវជននឹងធ្វើអោយមានការផ្លាស់ប្ដូរនូវអនាគតយ៉ាងពិតប្រាកដ

នាពេលអនាគត។

- សំនួរទី៥៖តើមានយុទ្ធសាស្ត្រអ្វីខ្លះដែលអាចលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងពង្រឹងកិច្ចការមូលដ្ឋាននិងអភិបាលកិច្ចល្អ?

  ដើម្បីលើកកម្ពស់តួនាទីរបស់យុវជនក្នុងការអភិវឌ្ឍថ្នាក់ក្រោមនិងអភិបាលកិច្ចល្អ គួរតែបង្កើតនូវវេទិកាសិក្ខាសាលា និងការពិភាក្សាតុមូលដែលជាឱកាសសម្រាប់ផ្លាស់ប្តូរយោបល់និងបទពិសោធន៍គ្នាទៅវិញទៅមក សម្រាប់ធ្វើការជាមួយយុវជន។ ជាពិសេសជាងនេះទៅទៀតលើកកម្ពស់ការផ្សព្វផ្សាយជាសាធារណៈ និងមិត្តអប់រំមិត្ត ដើម្បីទាក់ទាញយកចំណាប់អារម្មណ៍និងជាពិសេសធ្វើការបង្ហាញនូវលទ្ធផលស្នាដៃរបស់យុវជនគំរូៗក្នុងការដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ ហើយវានឹងធ្វើអោយយុវជនដ៏ទៃទៀតកាន់តែមានចំណាប់អារម្មណ៍បន្ថែមទៀត។

## ៨. ការវាយតម្លៃនៃវេទិកាពិភាក្សា

យុវជន ក្រុមប្រឹក្សាឃុំសង្កាត់ និងវាគ្មិនបានស្វែងយល់ពីបទពិសោធន៍ជាក់ស្តែងពីគ្នាទៅវិញទៅមក និងចូលរួមយ៉ាងសកម្មក្នុងការបញ្ចេញមតិដើម្បីស្វែងរកដំណោះស្រាយមួយដើម្បីឲ្យមានការចូលរួមដ៏ល្អរវាងយុវជននិងក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងការអភិវឌ្ឍមូលដ្ឋាននិងអភិបាលកិច្ចល្អ។តាមរយៈលទ្ធផលនៃការវាយតម្លៃដែលបានបំពេញដោយអ្នកចូលរួមនាចុងបញ្ចប់វេទិកាបានឆ្លុះបញ្ចាំងថា ៥០%នៃអ្នកចូលរួមបង្ហាញថា វេទិកាពិភាក្សានេះពិតជាមានសារប្រយោជន៍ណាស់ ខណៈដែល២១% ឆ្លើយថាមានប្រយោជន៍។ កម្រិតយល់ដឹងរបស់អ្នកចូលរួមទាក់ទងនឹងប្រធានបទមាន៧០.៤%។ តាមរយៈការវាយតម្លៃនេះដែរក៏បានបង្ហាញថា អ្នកចូលរួមបានរៀនពីតួនាទីរបស់យុវជន ក្នុងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចល្អនៅក្នុងសង្គមកញ្ចប់ថវិកាដែលត្រូវបែងចែក អភិបាលកិច្ចល្អ ផែនការ ការអនុវត្ត គោលនយោបាយកម្មវិធី សេវាកម្មប្រកបដោយគុណភាពខ្ពស់នៅថ្នាក់ក្រោមជាតិជាពិសេសនៅក្នុងកម្រិតសង្កាត់ ឫសគល់នៃអភិបាលកិច្ចល្អ ផែនការអភិវឌ្ឍឃុំរយៈពេលខ្លី និងរយៈពេលវែង តួនាទីយុវជននិងតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការពិភាក្សាដោយមានការចូលរួមជាមួយប្រជាជនមូលដ្ឋាន និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគមន៍ គម្រោងការពិភាក្សានៃការអភិវឌ្ឍ និងបទពិសោធន៍ការងាររបស់វាគ្មិននិងយុវជនជាដើម។ អង្គការវិទ្យាស្ថានបើកទូលាយ និងសម្ព័ន្ធភាពជាតិឃុំ សង្កាត់សង្ឃឹមថាអ្នកចូលរួមនឹងទទួលយកចំណេះដឹងនិងបទពិសោធន៍បន្ថែមពីវេទិកាពិភាក្សាយកទៅប្រើប្រាស់អោយមានប្រយោជន៍និងដើម្បីជំរុញកំណើនយុវជនចូលរួមកាន់តែច្រើនឡើងក្នុងការងារអភិវឌ្ឍន៍មូលដ្ឋាន តាមរយៈការជំរុញ និងពង្រឹងការពិភាក្សារវាងស្ថាប័នរដ្ឋ និងសង្គមស៊ីវិលលើកនេះ។

ភ្នំពេញថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១៣

អ្នកធ្វើរបាយការណ៍

លោក ថេន ឌីន

ជំនួយការគម្រោងការពិភាក្សាអំពីការអភិវឌ្ឍន៍

ពិនិត្យ កែសម្រួល និងឯកភាពដោយ៖

លោកស្រី ជឹម ម៉ាណាវី

នាយិកាប្រតិបត្តិអង្គការវិទ្យាស្ថានបើកទូលាយ

កញ្ញា កាំង សាណារី

ប្រធានគម្រោងការពិភាក្សាអំពីការអភិវឌ្ឍន៍

ជំនួយការទូទៅ៖

លោក ថេន ឌីន

ជំនួយការគម្រោងការពិភាក្សាអំពីការអភិវឌ្ឍន៍

រូបភាព និងបច្ចេកទេស៖

លោក អេង វណ្ណៈ អ្នកគ្រប់គ្រងតំបន់បណ្តាញ និងជំនួយការបច្ចេកទេស

## ឧបសម្ពន្ធ១៖

# បញ្ជីរាយនាមអ្នកចូលរួមវេទិកាពិភាក្សា
# ស្តីពី"តួនាទីយុវជនក្នុងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន"
# កាលបរិច្ឆេទ៖ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៣

| លរ | ឈ្មោះសិក្ខាកាម | ភេទ | តួនាទី | ស្ថាប័ន/អង្គការ |
|---|---|---|---|---|
| ១ | ឌុច ម៉ាលីន | ស្រី | មេឃុំ | ខេត្តសៀមរាប |
| ២ | សាម ឡុន | ប្រុស | ចៅសង្កាត់សាលាកំរើក | ខេត្តសៀមរាប |
| ៣ | គឹម លី | ស្រី | មេឃុំ តាគោក | ខេត្តបាត់ដំបង |
| ៤ | យារ ឡេង | ប្រុស | ចៅសង្កាត់កំពង់សំណាញ់ | ខេត្តកណ្តាល |
| ៥ | ឯល សាឡែស | ប្រុស | ចៅសង្កាត់ស្លាកែត | ខេត្តបាត់ដំបង |
| ៦ | សៀម វត្ថរិទ្ធិ | ប្រុស | មិត្តអប់រំមិត្ត | សមាគម PHD |
| ៧ | គឹម សុភ័ក្រ | ស្រី | មិត្តអប់រំមិត្ត | សមាគម PHD |
| ៨ | រិទ្ធ សុវណ្ណកា | ស្រី | N/A | អង្គការ KYSD |
| ៩ | សាន ណៃនី | ស្រី | មិត្តអប់រំមិត្ត | អង្គការ KYSD |
| ១០ | សុខ ហេង | ប្រុស | មិត្តអប់រំមិត្ត | សមាគម PHD |
| ១១ | គង់ រដ្ឋា | ប្រុស | មន្ត្រីគម្រោង | អង្គការ KYSD |
| ១២ | លី សុវណ្ណ | ប្រុស | អ្នកស្ម័គ្រចិត្ត | អង្គការ KYSD |
| ១៣ | ហ៊ន សុវណ្ណចិន្តា | ស្រី | និស្សិត | អង្គការ YRDP |
| ១៤ | នៅ វុទ្ធី | ប្រុស | និស្សិត | អង្គការ YRDP |
| ១៥ | តក គឹមសុង | ប្រុស | បុគ្គលិក | សមាគម KYA |
| ១៦ | ស្រស់ ណូ | ប្រុស | មន្ត្រីគម្រោង | សមាគម PHD |
| ១៧ | ហេង សុខអេង | ប្រុស | អ្នកស្ម័គ្រចិត្ត | អង្គការ KYSD |
| ១៨ | សាក់ សំកុល | ប្រុស | ក្រុមប្រឹក្សា ទួលស្វាយព្រៃ១ | ចំការមន រាជធានីភ្នំពេញ |
| ១៩ | ឃួន សុផុន | ប្រុស | ចៅសង្កាត់ទួលទំពូងទី២ | ចំការមន រាជធានីភ្នំពេញ |
| ២០ | លី ម៉ី | ស្រី | មិត្តអប់រំមិត្ត | សមាគម PHD |
| ២១ | Katja Sarajeva | ស្រី | អ្នកស្រាវជ្រាវ | SPIDER |

| | | | | |
|---|---|---|---|---|
| ២២ | នុប លីនដា | ស្រី | លេខា | អង្គការ VOD |
| ២៣ | ចាន់ សុគន្ធា | ស្រី | អ្នកស្រាវជ្រាវ | Freelance |
| ២៤ | កៀវ រុំម៉ូនី | ស្រី | មិត្តអប់រំមិត្ត | សមាគម PHD |
| ២៥ | ហ៊ន សុខសុវណ្ណបុប្ផា | ស្រី | ជំនួយការគណនេយ្យ | អង្គការ Star Kampuchea |
| ២៦ | ហេង សុគន្ធា | ស្រី | អ្នកសម្របសម្រួលគម្រោង | អង្គការ KYSD |
| ២៧ | សរ សុធារុំ | ស្រី | មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ | អង្គការ Youth Star |
| ២៨ | ព្រេជ ចំណាស់ | ប្រុស | បុគ្គលិក | អង្គការ API |
| ២៩ | ព្រំ សុជាតិ | ប្រុស | បុគ្គលិក | វិទ្យុ Sarika FM |
| ៣០ | ឈៀន ចាន់ហៀង | ប្រុស | មន្ត្រីគម្រោង | អង្គការ KYSD |
| ៣១ | ចាន់ សេដ្ឋា | ស្រី | មន្ត្រីគម្រោង | អង្គការ YRDP |
| ៣២ | ថុង តុលា | ប្រុស | មន្ត្រីគម្រោង | ក្រសួងកិច្ចការនារី |
| ៣៣ | ថយ ម៉ូនីរេដ | ស្រី | សមាជិក មន្ត្រីសេវា | អង្គការ CCC |
| ៣៤ | ប៉ិត វណ្ណ | ស្រី | មេឃុំ | ខេត្តកណ្តាល |
| ៣៥ | គ្រី សាំងហេង | ប្រុស | និស្សិត | អង្គការ YRDP |
| ៣៦ | វ៉ែន ឌី | ប្រុស | ពិធីករ | វិទ្យុ Sarika FM |
| ៣៧ | សុខ សូធី | ប្រុស | អនុប្រធានអង្គភាព | NCDDs |
| ៣៨ | ជឹម ម៉ាណារី | ស្រី | នាយិកាប្រតិបត្តិ | វិទ្យាស្ថានបើកទូលាយ |
| ៣៩ | កាំង សាណារី | ស្រី | ប្រធានគម្រោង | វិទ្យាស្ថានបើកទូលាយ |
| ៤០ | ចេត ឌីន | ប្រុស | ជំនួយការគម្រោង | វិទ្យាស្ថានបើកទូលាយ |